គណបក្ស សម រង្ស៊ី នៃ រដ្ឋរ៉ូដអៃឡិន្ត/ហ្វលរីវើ សហរដ្ឋអាមេរិក
The Sam Rainsy Party-Rhode Island/Fall River United States of America
សីលធម៌ សច្ចធម៌ យុត្តិធម៌ Integrity Honesty Justice

# សេចក្តីប្រកាសព័ត៌មាន

ទីក្រុងប្រូវីដិនស៍ សហរដ្ឋអាមេរិក 　　　　　　　　　　 ០៧ កុម្ភៈ ព.ស.២៥៥៥/គ.ស.២០១២

គណបក្ស សម រង្ស៊ី ប្រចាំរដ្ឋរ៉ូដអៃឡិន្ត-ហ្វលរីវើ (គ.ស.រ.-រអ/ហ្វ) មានកិត្តិយសសូមទូលប្រគេនព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ និងជម្រាបជូនលោក លោកស្រី អ្នកនាង កញ្ញា សមាជិកគណបក្ស បងប្អូនជនរួមជាតិ បណ្តាញសារព័ត៌មាន និងសាធារណជនជ្រាបថា គ.ស.រ.-រអ/ហ្វ នឹងប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរថ្មី ឆ្នាំរោងចត្វាស័ក ព.ស.២៥៥៦/គ.ស.២០១២ តាមទំនៀមទម្លាប់ដូចមាននៅរៀងរាល់ឆ្នាំ នៅសាលព័រទុហ្គេស៍ ស្ថិតនៅអាសយដ្ឋាន ២០ Second Avenue, ទីក្រុងក្រេនស្តិន រដ្ឋរ៉ូដអៃឡិន្ត នាថ្ងៃសៅរ៍ ០១រោច ខែចេត្រ ឆ្នាំថោះត្រីស័ក ព.ស.២៥៥៥ ត្រូវនឹងថ្ងៃទី០៧ ខែមេសា គ.ស.២០១២។ នៅថ្ងៃដដែលនោះ មានកម្មវិធីពីរវគ្គ: កម្មវិធីពេលព្រឹក វេលាម៉ោង ៨:៣០នាទីព្រឹក ដល់ម៉ោង ២:០០នាទីរសៀល មានពិធីព្រះពុទ្ធសាសនាតាមទំនៀមទម្លាប់ខ្មែរ។ កម្មវិធីល្ងាច វេលាម៉ោង ៦:០០នាទីល្ងាច ដល់ម៉ោង ១២:០០អធ្រាត្រ មានពិធីជប់លៀងចូលឆ្នាំថ្មីនិងរាំកម្សាន្តជាមួយតន្ត្រីសម័យ។

សេចក្តីប្រកាសនេះចាត់ទុកជាការអញ្ជើញលោក លោកស្រី អ្នកនាង កញ្ញា សមាជិកគណបក្ស បងប្អូនជនរួមជាតិ និងសាធារណជនទៅចូលរួមក្នុងពិធីបុណ្យចូលឆ្នាំថ្មីខាងមុខនេះកុំបីអាក់ខានឡើយ។

គ.ស.រ.-រអ/ហ្វ ជាសាខាគណបក្ស សម រង្ស៊ីនៃទ្វីបអាមេរិកខាងជើង គាំទ្រ និងឧបត្ថម្ភដល់មាតាគណបក្ស សម រង្ស៊ី (គ.ស.រ.) ជាគណបក្សនយោបាយប្រជាធិបតេយ្យពិតប្រាកដ និងធំទីពីរ នៅព្រះរាជាណាចក្រកម្ពុជា។

វិភាគទានបានមកពីការប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរនេះ សម្រាប់ចូលរួមចំណែកជំរុញឱ្យមាតុភូមិកម្ពុជា មានគោលនយោបាយការពារបូរណភាពទឹកដីត្រឹមត្រូវ មានរបបប្រជាធិបតេយ្យពិតប្រាកដ មានតុលាការឯករាជ្យ មានប្រព័ន្ធបោះឆ្នោតឯករាជ្យ មានវប្បធម៌គោរពសិទ្ធិមនុស្សពិតប្រាកដ បំបាត់អំពើពុករលួយ និងផ្តល់ការងារជូនប្រជារាស្ត្រគ្រប់គ្រាន់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:

លោក សាយ សារ៉ាត់ ៤០១.៣៧៤.៧៩៩៣ លោក ប៊ុល ប្រសើរ ៤០១.៥៨៨.០៩៩៥ លោក អៀច ពុទ្ធី ៤០១.៤៦១.០២២៤ ឬលោក ផាន់ សារឿន ៤០១.២៨៦.៨៧២១ ឬអ៊ីមែល srpri@yahoo.com.

---

គណបក្សសម រង្ស៊ី នៃ រដ្ឋរ៉ូដអៃឡែន/ហ្វលរីវើ សហរដ្ឋអាមេរិក

**The Sam Rainsy Party-Rhode Island/Fall River United States of America**

សីលធម៌ សច្ចធម៌ យុត្តិធម៌ Integrity Honesty Justice

# Press Release

Providence, United States of America February 7, BE2555/AD2012

The Sam Rainsy Party-Rhode Island/Fall River (SRP-RI/FR) has an honor to inform you, members, media, compatriots and members of the public that SRP-RI/FR will organize a traditionally annual Khmer New Year Celebration, year of the Dragon B.E.2556, A.D.2012, at the Portuguese Club, 20 Second Avenue, Cranston, Rhode Island, on Saturday the 1st Waning Moon of Citta B.E.2555, April 7, A.D.2012. There will be two phases of celebration: Morning Program 8:30AM – 2:00PM Traditional Buddhist ceremony. Evening Program 6:00PM – 12:00Midnight New Year Party Celebration, dancing with live band.

This release is an open invitation to you, members, compatriots and the public.

SRP-RI/FR is a chapter of the Sam Rainsy Party-North America that supports the parent Sam Rainsy Party (SRP), the genuine democratic and second largest political party in the Kingdom of Cambodia.

Proceeds to benefit the Sam Rainsy Party in advancing Cambodia to establish a clear policy on protecting national territories, to become a true democratic country, independent court, independent electoral system, respect human and religious rights, eliminate all forms of corruption and provide adequate jobs.

Contact Information:
Sarath Say 401.374.7993, Praser Pel 401.588.0595, Puthy Iech 401.461.0224, Saroeun Phann 401.286.8721, or E-mail: srpri@yahoo.com.